# ពិធីសំពះព្រះខែរបស់ជាតិពិន្ទុខ្មែរ
# នៅខេត្តសុផាន់បុរី (សុវណ្ណបុរី) ប្រទេសថៃ

ពិធីបុណ្យសំពះព្រះខែជាពិធីបុណ្យមួយដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងជំនឿនៃសង្គមខ្មែរ។ យើងសង្កេតឃើញថាពិធីសំពះខែនេះមានរៀបចំឡើងនៅគ្រប់ស្រទាប់មនុស្សខ្មែរតាំងពីថ្នាក់ដឹងនាំកំពូលរបស់ប្រទេសរហូតដល់ប្រជាជនសមញ្ញជម្មតា ដោយគេតែងប្រារព្ធធ្វើពិធីសំពះព្រះខែនេះនៅថ្ងៃទី១៥ កើត ខែកត្តិក ជារៀងរាល់ឆ្នាំ។ ពិធីសំពះព្រះខែមិនត្រឹមតែមាននៅក្នុងប្រទេសបច្ចុប្បន្ននោះទេ តែយើងក៏ឃើញមានការរៀបចំកិច្ចពិធីនេះនៅក្នុងចំណោមជាតិពិន្ទុខ្មែរដែលរស់នៅក្នុងទឹកដីថៃបច្ចុប្បន្នផងដែរ។ ជាក់ស្តែងក្រុមជាតិពិន្ទុខ្មែរដែលរស់ក្នុងឃុំតុនពោធិ៍ ឃុំបឹងខាន់ និងឃុំតាលិងចាន់ នៃក្រុងសុផាន់បុរីប្រទេសថៃជាដើម។

តាមការស្រាវជ្រាវកន្លងមកបានឱ្យដឹងថា ជាតិពិន្ទុខ្មែរដែលបានមកតាំងទីលំនៅក្នុងខេត្តសុផាន់បុរីនេះ ប្រហែលជាប្រជាជនដែលសៀមកេណ្ឌពីបាត់ដំបងនៅក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនង់ក្លៅចៅយូហួ ឬស្តេចរាមាទី៣។ ហេតុការណ៍នេះកើតឡើងនៅពេលដែលមេទ័ពថៃឈ្មោះចៅពញាបឌិនតេជោ (សិង្ហ សិង្ហសេនី) ទទួលបញ្ជាពីស្តេចរាមាទី៣ឱ្យនាំព្រះអង្គអិមនិងព្រះអង្គឌួងលើកទ័ពមកខ្មែរដើម្បីច្បាំងនឹងយួននៅឆ្នាំ១៨៣២ តែការលើកទ័ពមកច្បាំងនៅគ្រានោះ ទ័ពសៀមមិនទទួលបានជោគជ័យទេ។ ក្រោយមកមេទ័ពសៀមបានលើកទ័ពមកតាំងនៅបាត់ដំបង និងបាននាំព្រះអង្គអឹមនិងព្រះអង្គឌួងមកគង់នៅបាត់ដំបង។ ចំណែកមេទ័ពសៀមរូបនេះក៏បានដកទ័ពទៅបាងកកវិញ ព្រមទាំងបានកេណ្ឌប្រជារាស្ត្រខ្មែរមួយចំនួនទៅជាមួយផង។[១] ប្រជារាស្ត្រដែលសៀមបានកេណ្ឌទៅ ត្រូវគេបញ្ជូនឱ្យទៅរស់នៅម្តុំខេត្តសុផាន់បុរីនេះឯង។[២] ហេតុការណ៍នេះក៏ត្រូវគ្នានឹងកំណត់ហេតុអំពីរឿងក្តីរបស់ស្ត្រីខ្មែរម្នាក់ឈ្មោះប៉ែនដែលត្រូវគេកេណ្ឌពីបាត់ដំបងឱ្យមករស់នៅសុផាន់បុរីនៅសម័យស្តេចរាមាទី៣។ នាងប៉ែនបានលួចមាន

---

[១] เจ้าพระยาทิพากรวงศมหาโกษาธิบดี 1995, 132-140.

[២] สุภาภรณ์ จินดามณีโรจน์ 1989, 35-39.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

ស្នេហ៍ជាមួយអន្ទិតយេមដែលទើបនឹងសឹកថ្មីៗ ហើយប្រុងនឹងនាំគ្នារស់ទៀតផង។[៣] តាមរយៈកំណត់ហេតុនេះធ្វើឱ្យដឹងថា ពិតជាមានប្រជាជនខ្មែរដែលត្រូវគេកេណ្ឌពីបាត់ដំបងមករស់នៅក្នុងខេត្តសុផាន់បុរីមែន។

ពិធីសំពះព្រះខែនៃជាតិពិន្ទុខ្មែរនៅខេត្តសុផាន់បុរីតែងរួមគ្នាធ្វើពិធីនៅតាមវត្តអារាមនៃទីប្រជុំជនរៀងៗខ្លួន ដូចជា វត្តសាមចង់ក្នុងឃុំតាលិងឆាន់ និងវត្តប្រជុំជនក្នុងឃុំបានពោធិ៍។ ដោយឡែកកិច្ចពិធីសំពះព្រះខែវិញក៏មានលក្ខណៈខុសគ្នាតិចតួចទៅតាមតំបន់រៀងខ្លួនដែរ និងមិនមានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងកិច្ចពិធីសំពះព្រះខែនៅកម្ពុជាដែរ។ យ៉ាងណាក្តីយើងនៅតែអាចសង្កេតឃើញលក្ខណៈរួមគ្នារវាងពិធីសំពះព្រះខែនៅកម្ពុជា និងនៅសុផាន់បុរីបានយ៉ាងច្បាស់ដែរ។

ពិធីសំពះព្រះខែរបស់ជាតិពិន្ទុខ្មែរនៅសុផាន់បុរីរៀបចំឡើងនៅថ្ងៃទី១៥កើត ខែកត្តិក ជារៀងរាល់ឆ្នាំដូចខ្មែរនៅកម្ពុជាដែរ។ ប៉ុន្តែនៅមុនថ្ងៃប្រារព្ធពិធីមួយថ្ងៃ ព្រះសង្ឃបានដឹកនាំប្រជាជនក្នុងភូមិ ដើម្បីរៀបចំតុបតែងលម្អទីតាំងប្រារព្ធពិធី ដោយគេជ្រើសរើសទីតាំងដែលស្រឡះល្អនៅក្នុងវត្ត ដើម្បីអាចមើលឃើញព្រះច័ន្ទបានយ៉ាងច្បាស់អំឡុងកិច្ចពិធីនៅពេលយប់។ នៅវត្តខ្លះដូចវត្តសាមចង គេមានរៀបចំធ្វើរាជវតិដោយមានប្រកចូលចំនួនពីរៗ នៅតាមទិសធំទាំង៤ ផ្នែកខាងក្នុងរាជវតិមានរៀបចំអាសនៈសម្រាប់តម្កល់ព្រះពុទ្ធរូប និងអាសនៈសម្រាប់ព្រះសង្ឃគង់ នៅខាងមុខអាសនៈសង្ឃជាកន្លែងអង្គុយរបស់អ្នកស្រុក (រូបលេខ១)។ ចំណែកវត្តខ្លះមិនមានធ្វើរាជវតិទេ តែគេរៀនអាសនៈព្រះសង្ឃនៅក្នុងពេងតូចមួយនៅកណ្តាលផ្លាវត្តវិញ។ នៅខាងក្រៅរាជវតិទល់មុខអាសនៈរបស់ព្រះសង្ឃ មានរៀបចំស្នួមួយមានកម្ពស់ត្រឹមក្បាលសម្រាប់ដោតទៀតផ្សងទឹកភ្លៀង (រូបលេខ២)។

[៣] ชัชพิสิฐ ปาชะนี 2021, 423-424.

អត្ថបទដោយៈ ឡេង ស៊ីវ៉ង់



រូបភាពទី១៖ ទីតាំងប្រារព្ធពិធីសំពះព្រះខែវត្តសាមថង (រូបថត៖ ชายพงษ์ เด็กเมืองเหน่อ)


រូបភាពទី២៖ ស្នួសម្រាប់ដោតទៀតផ្សងទឹកភ្លៀង វត្តប្រជុំជន

(រូបថត៖ ศูนย์ข้อมูลสารสนเทศคณะสงฆ์ภาค ๑๔)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

*នៅព្រឹកថ្ងៃបន្ទាប់ដែលជាថ្ងៃប្រារព្ធពិធី គេរៀបចំសិតទៀនសម្រាប់ធ្វើពិធីផ្សងទឹកភ្លៀងនៅពេលពាក់កណ្តាលយប់។ ចំពោះការសិតទៀនវិញ គឺធ្វើឡើងដោយព្រះសង្ឃ និងព្រឹទ្ធាចារ្យដែលជាចាស់ទុំនៅក្នុងភូមិដែលមាននាទីរៀបចំកិច្ចពិធី ដោយគេយកក្រមួនទៀនដែលព្រះសង្ឃដុតសល់អំឡុងពេលចូលវស្សាមកស្ងោរលាយជាមួយនឹងក្រមួនទៀនដែលសល់ពីការដុតផ្សងទឹកភ្លៀងពីឆ្នាំទៅ។ បន្ទាប់មកគេយកទឹកទៀនដែលរលាយនោះមកច្រកក្នុងពុម្ពទៀនដែលជាបំពង់ឫស្សីទំហំប៉ុនគ្នា ដោយមានអំបោះធៅ៩សរសៃធ្វើស្នូលនៅចំកណ្តាលផង។ ក្រោយពីទៀនរឹងល្អហើយ គេយកទៀនមកថ្លឹងឱ្យស្មើគ្នា កាលបើលើស គេត្រូវកោសយកសាច់ចេញឱ្យទាល់តែទម្ងន់ស្មើគ្នា។ ចំនួនទៀនអាចមាន៣ដើម ៦ដើម ឬ១២ដើមនៅតាមការកំណត់នៃវត្តនីមួយៗ។ ជាក់ស្តែងនៅវត្តសាមថងប្រើទៀន៣ដើម វត្តប្រជុំជនប្រើទៀន៦ដើម និងវត្តឥន្ទ្រក្សេមប្រើទៀន១២ដើម ជាដើម។[៩]*

*ចំពោះគ្រឿងតង្វាយសំខាន់ដែលអ្នកស្រុកនាំយកមកប្រគេនព្រះសង្ឃនិងសម្រាប់ថ្វាយដល់ទេវតារួម ចេក អំបុក និងក្រឡាន។ អ្នកស្រុកនាំយកក្រឡាន អំបុកនិងចេកទៅដាក់នៅក្នុងចានដែក ឬកញ្ចេដែលវត្តបានត្រៀមទុកនៅក្នុងរោងពិធី ឬវត្តខ្លះរៀបអំបុកនឹងចេកដាក់ចានដោយឡែកសម្រាប់ព្រះសង្ឃបាចនៅអំឡុងពេលកិច្ចពិធី* ***(រូបលេខ៣)***។ *នៅវេលាជិតពាក់កណ្តាលអធ្រាត្រ អ្នកដំណើរការកិច្ចពិធី៣នាក់ស្លៀកសពាក់សដែលគេសន្មតថាជា ព្រាហ្មណ៍ នឹងនាំអ្នកស្រុកសូត្រមន្តសមាទានសីល។ ក្រោយសមាទានសីលចប់ ព្រាហ្មណ៍សូត្រអញ្ជើញទេវតា ម្ចាស់ទឹកម្ចាស់ដី វត្ថុស័ក្តិសិទ្ធិ ឱ្យមកទទួលដង្វាយដែលអ្នកស្រុកបានរៀបថ្វាយ។ នៅពេលព្រះច័ន្ទរះចំត្រង់ក្បាលហើយ ព្រាហ្មណ៍ក៏អារាធនាព្រះសង្ឃចម្រើនព្រះបរិត្ត និងចាប់ផ្តើមដុតទៀតដើម្បីផ្សងទឹកភ្លៀងផងដែរ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺ នៅអំឡុងពេលសម្រក់ទៀនផ្សងទឹកភ្លៀងនោះ ព្រះសង្ឃក៏ចាប់ផ្តើមបាចអំបុកនិងចេកមកលើអ្នកស្រុកដែលកំពុងអង្គុយស្តាប់ព្រះបរិត្ត****(រូបលេខ៤)***

---

[៩] *សូមអានបន្ថែមនៅ* www.finearts.go.th/suphanburiarchives/view/7366-ประเพณีไหว้พระแข-วัดสามทอง-ตำบลตลิ่งชัน-อำเภอเมืองสุพรรณบุรี-จังหวัดสุพรรณบุรี

*អត្ថបទដោយៈ ឡេង ស៊ីវ៉ង់*

ដោយការបាចនេះអ្នកស្រុកពន្យល់ថា ជានិមិត្តរូបដំណាងឱ្យទឹកភ្លៀងដែលធ្លាក់មក[៥] ដែលប្រការនេះមានទំនាក់ទំនងនឹងរឿងភោគផល។ ទំនៀមដែលព្រះសង្ឃបាចអំបុកបែបនេះ យើងក៏ឃើញមានធ្វើនៅតំបន់ខ្លះក្នុងខេត្តកំពង់ចាមនិងខេត្តសៀមរាបនៃប្រទេសកម្ពុជាដែរ។[៦]



រូបភាពទី៣៖ ក្រឡាន អំបុក និងចេកដែលអ្នកស្រុកយកទៅធ្វើកិច្ចពិធីនៅវត្តប្រជុំជន

(រូបថត៖ ศูนย์ข้อมูลสารสนเทศคณะสงฆ์ภาค ๑๔)

---

[៥] เอกรินทร์ พึ่งประชา 2004, 264.

[៦] អាំង ជូលាន ២០១២-២០១៣, ៣៩-៤២។

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង



រូបភាពទី៤៖ ព្រះសង្ឃបាចអំបុកនិងចេកក្នុងពិធីសំពះព្រះខែវត្តសាមថង

(រូបថត៖ ชายพงษ์ เด็กเมืองเหน่อ)

របៀបព្យាករណ៍អំពីដំណើរទឹកភ្លៀងរបស់ព្រាហ្មណ៍ទាំង៣មិនមានអ្វីខុសពីខ្មែរនៅកម្ពុជាទេ ដោយទៀននីមួយៗ គេតំណាងឱ្យរយៈពេលនៃរដូវភ្លៀង។ ឧទាហរណ៍នៅវត្តសាមថង គេប្រើទៀនចំនួន៣ដើម ដោយទៀនទី១តំណាងឱ្យដើមរដូវវស្សាដែលមានរយៈពេល២ខែ ទៀនទី២តំណាងឱ្យពាក់កណ្ដាលរដូវវស្សាដែលមានរយៈពេល២ខែ និងទៀនទី៣តំណាងឱ្យចុងរដូវវស្សាដែលមានរយៈពេល២ខែដែរ។[៧] កាលណាបើទឹកទៀននីមួយៗស្រក់ខ្លាំងគេកំណត់ថាមានភ្លៀងច្រើននៅតាមរដូវមួយៗ តែបើទឹកទៀនស្រក់យឺតគេកំណត់ថាមានភ្លៀងតិច(រូបភាព។ ដូចនេះការសម្រក់ទៀងដើម្បីផ្សងពីដំណើរទឹកភ្លៀងនោះ ពិតណាស់គឺធ្វើឡើងដើម្បីចង់ដឹងពីភោគផលរបស់កសិករសម្រាប់ឆ្នាំក្រោយតាមរយៈការមើលលទ្ធផលនៃការផ្សងទឹកភ្លៀង។ ប្រការនេះមិនមានអ្វីខុសគ្នាពីគំនិតនៃសម្រក់ទៀនផ្សងទឹកនៅកម្ពុជានោះទេ។[៨]

---

[៧] បទសម្ភាសលោកតាគ្រិន នៅថ្ងៃទី២២ មិថុនា ២០១៦។

[៨] អាំង ជូលាន ២០១២-២០១៣, ៣៧-៤២។ ហៀន សុវណ្ណមរកត ២០២២។

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង

តាមរយៈទំនៀមសំពះព្រះខែរបស់ជាតិពិន្ទុខ្មែរនៅខេត្តសុផាន់បុរីបានឆ្លុះបញ្ចាំងឱ្យឃើញអំពី ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងជីវភាពរស់នៅរបស់ខ្មែរជាមួយនឹងការងារកសិកម្ម បើទោះបីជាមានការផ្លាស់ប្ដូរទីកន្លែងរស់នៅយ៉ាងណាក៏ដោយ។ ការប្រតិបត្តិទំនៀមទម្លាប់ប្រពៃណីដែលទាក់ទងនឹងកសិកម្មមួយនេះនៅតែមានជីវិតយ៉ាងរស់រវើកក្នុងពីជីវភាពរស់នៅរបស់មនុស្សខ្មែរនៅសុផាន់បុរី៕

## បញ្ជីឯកសារយោង


ហៀន សុវណ្ណមរកត.

២០២២, https://ams.com.kh/khmercivilization/detail/25124។

អាំង ជូលាន.

២០១២-២០១៣, "សំពះព្រះខែ" កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ៨, ទំ.៣៧-៤២, យសោធរ, ភ្នំពេញ។

តា គ្រិន.

២២ មិថុនា ២០១៦, បទសម្ភាសនៅភូមិ២ ឃុំតាលិងចាន់ ក្រុងសុផាន់បុរី ខេត្តសុផាន់បុរី ប្រទេសថៃ។

เจ้าพระยาทิพากรวงศมหาโกษาธิบดี

1995, พระราชพงศาวดารกรุงรัตนโกสินทร์รัชกาลที่ ๓, กรุงเทพฯ: อมรินทร์พริ้นติ้งฯ.

ชัชพิสิฐ ปาชะนี

2021, การศึกษาวิเคราะห์ลักษณะและสารัตถะของเอกสารตัวเขียนที่ใช้ในการติดต่อข้อราชการระหว่างไทยและกัมพูชาในช่วง พ.ศ. 2325-2427. (วิทยานิพนธ์ปริญญาดุษฎีบัณฑิต) คณะโบราณคดี, มหาวิทยาลัยศิลปากร.

สุภาภรณ์ จินดามณีโรจน์

1989, รายงานการวิจัยประวัติศาสตร์ของชุมชนในลุ่มน้ำท่าจีน, หมวดประวัติศาสตร์ คณะโบราณคดี มหาวิทยาลัยศิลปากร.


អត្ថបទដោយៈ ឡេង ស៊ីវ៉ង់

หอจดหมายเหตุแห่งชาติจังหวัดสุพรรณบุรี

www.finearts.go.th/suphanburiarchives/view/7366-ประเพณีไหว้พระแข-วัดสามทอง-ตำบลตลิ่งชัน-อำเภอเมืองสุพรรณบุรี-จังหวัดสุพรรณบุรี

เอกรินทร์ พึ่งประชา

2004, "ไหวพระแขบ้านตลิ่งชัน เทคโนโลยี, อำนาจ และการต่อรองของพิธีกรรมเปลี่ยนผ่าน" *ดำรงวิชาการ*, ปีที่3 ฉบับที่5. น.261-270, คณะโบราณคดี, มหาวิทยาลัยศิลปากร.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយៈ ឡេង ស៊ីវ៉េង